បណ្ដាញនវានុវត្តន៍ សម្រាប់សន្តិសុខស្បៀង និងការកាត់បន្ថយភាពក្រីក្រ

# ដើមសង្រ្កងស្វាមានប្រសិទ្ធភាពប្រឆាំងនឹងការបំផ្លាញ ដំណាំម្ទេសដោយដង្កូវ Nematode នៅអាស៊ីអាគ្នេយ៍

ឯកសារបច្ចេកវិទ្យា

ថ្ងៃទី០១ ខែតុលា ឆ្នាំ២០១៤

## ចំណុចគន្លឹះ៖

- ប្រើប្រាស់លក្ខណៈធម្មជាតិនៃដើមសង្រ្កងស្វាដើម្បីកម្ចាត់ដង្កូវ Nematode ក្នុងការដាំដំណាំម្ទេស។
- កាត់បន្ថយការពឹងផ្អែកលើ និងការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតដែលមានជាតិគីមី។




ក្រាហ្វិកនេះសង្ខេបអំពីលទ្ធផលនៃការវាយតម្លៃនិរន្តភាពដែលបានធ្វើឡើងសម្រាប់បច្ចេកវិទ្យានេះ។ ប្រសិនបើខ្សែបន្ទាត់ខិតកាន់តែជិតជ្រុងខាងក្រៅនៃដ្យាក្រាមនេះ នោះមានន័យថាការអនុវត្តបច្ចេកវិទ្យានេះកាន់តែប្រសើរពាក់ព័ន្ធនឹងលក្ខណៈវិនិច្ឆ័យជាក់លាក់។

## ការពណ៌នា

- Nematodes (*Phylum nematode*) ឬហៅថាដង្កូវមូលគឺជាសារពាង្គកាយពហុកោសិកាដែលមានហ្សែនច្រើន និងចម្រុះគ្នាបំផុត។ ដង្កូវប្រភេទនេះ ភាគច្រើនគឺជាសមាជិកនៃប្រព័ន្ធអេកូឡូស៊ីដែលមានឥទ្ធិពលវិជ្ជមាន។
- ពូជដង្កូវ Nematode មួយចំនួនគឺជាបរាសិតដែលរស់នៅក្នុងខ្លួនមនុស្ស បសុសត្វ ឬដំណាំកសិកម្ម។ ដង្កូវស៊ីឫសដង្កូវធ្វើឲ្យមានជំងឺពកនៅឫសដំណាំ (cyst) និងដង្កូវធ្វើឲ្យខូចឫស ដំណាំ (lesion) គឺជាសត្វល្អិតចង្រៃចំពោះប្រភេទដំណាំជាច្រើនប្រភេទ និងធ្វើឲ្យខាតបង់ដំណាំដែលមានតម្លៃរាប់ពាន់លានដុល្លារអាមេរិកក្នុងមួយឆ្នាំៗ។
- ដើមសង្រ្កងស្វា (ប្រភេទរុក្ខជាតិតិណទេស និងចុល្លព្រឹក្សានៅក្នុងគ្រួសារ Fabaceae ដែលជាទូទៅហៅថា rattlepods) គឺជាដំណាំទាក់ទាញសត្វល្អិតចង្រៃដែលកាត់បន្ថយដង្កូវ Nematode នៅក្នុងដី។
- ការដាំដើមសង្រ្កងស្វា និងការលាយជីវម៉ាសដែលមានដើម សង្រ្កងស្វានៅក្នុងដីនោះមុនពេលដាំម្ទេសអាចកម្ចាត់ការបំផ្លាញដោយដង្កូវ Nematode នៅក្នុងតំបន់ត្រូពិកដូចបានបង្ហាញនៅភាគព្យសាននៃប្រទេសថៃ។

រូបភាពទី១៖ ដើមសង្រ្កងស្វា *(Crotalaria juncea)* នៅក្នុងចម្ការ[១]



រូបភាពទី២៖ ផ្កាសង្រ្កងស្វា (ឈ្មោះបច្ចេកទេស *C. juncea*)[២]



[១]រូបថត៖ A16898. http://commons.wikimedia.org/wiki/File:Crotalaria_juncea_D9991.jpg

[២]រូបថត៖ A16898. http://commons.wikimedia.org/wiki/File:Crotalaria_juncea_Da220020.JPG

## ប្រវត្តិបច្ចេកវិទ្យា

- នៅភាគឦសានប្រទេសថៃកសិករទទួលរងការធ្លាក់ចុះនូវទិន្នផលពីដំណាំម្ទេស (*Capsicum spp*) យ៉ាងខ្លាំងដោយសារការបំផ្លាញរបស់ដង្កូវ Nematode (*Meloidogyne incognita*) ដែលបង្ខំឲ្យកសិករដាំដំណាំផ្សេងជំនួសវិញឬឈប់ដាំម្ទេសតែម្តង។
- ដើមសង្រ្កងស្វាត្រូវបានបង្ហាញថាមានប្រសិទ្ធភាពក្នុងការកម្ចាត់ដង្កូវ Nematode នៅក្នុងតំបន់អាកាសធាតុបង្គួរប៉ុន្តែមិនទាន់មានភ័ស្តុតាងគ្រប់គ្រាន់ដែលបង្ហាញអំពីប្រសិទ្ធភាពនៃដើមសង្រ្កងស្វានេះនៅក្នុងតំបន់ត្រូពិកនៅឡើយ។
- មជ្ឈមណ្ឌលស្រាវជ្រាវអន្តរជាតិសម្រាប់វិទ្យាសាស្រ្តកសិកម្មជប៉ុន (JIRCAS) បានវាយតម្លៃអំពីប្រសិទ្ធភាពរបស់ដើមសង្រ្កងស្វានេះ ក្នុងការចាត់វិធានការកាត់បន្ថយការបំផ្លាញ ដោយសារដង្កូវ Nematode នៅក្នុងតំបន់ត្រូពិក។[៣]
- ដើម Sunn hemp (*Crotalaria juncea*)មានប្រសិទ្ធភាពខ្ពស់ក្នុងការកម្ចាត់ដង្កូវ Nematode ដែលបំផ្លាញដំណាំម្ទេសនៅក្នុងចម្ការពិសោធន៍។

## កន្លែងអនុវត្តបច្ចេកវិទ្យា

- បច្ចេកវិទ្យានេះអាចដំណើរការល្អក្នុងតំបន់ដែលមានដំណាំម្ទេសនៅតំបន់ត្រូពិកដែលទទួលរងការបំផ្លាញពីដង្កូវ Nematode ដូចជាភាគឦសាននៃប្រទេសថៃជាដើម។
- អ្នកអនុវត្តតាមជោគជ័យគឺជាកសិករដាំម្ទេសនៅភាគឦសាននៃប្រទេសថៃដែលបានចូលរួមនៅក្នុងសិក្ខាសាលាដែលរៀបចំឡើងដោយរដ្ឋាភិបាលថៃនិងបានទទួលគ្រាប់ពូជដើមសង្រ្កងស្វា។ អ្នកមិនអនុវត្តបច្ចេកវិទ្យានេះមិនបានចូលរួមក្នុងសិក្ខាសាលានេះឡើយហើយក៏មិនបានទទួលគ្រាប់ពូជសង្រ្កងស្វាដែរ។
- នៅក្នុងប្រទេសថៃកសិករបានរៀនសូត្របច្ចេកវិទ្យានេះពីមន្ទីរកសិកម្មនៃក្រសួងកសិកម្ម និងសហករណ៍។

## ទិដ្ឋភាពបច្ចេកវិទ្យា

- ក្រោយពេលរៀបចំដីរួច និងយ៉ាងហោចណាស់រយៈពេលពីរខែមុនពេលដាំដំណាំម្ទេសត្រូវសាបព្រោះគ្រាប់ដើមសង្រ្កងស្វាយ៉ាងហោចណាស់ចំនួន៣១គីឡូក្រាមក្នុងមួយហិកតាដោយអាស្រ័យលើលក្ខខណ្ឌទីតាំងដី។ ជាការសំខាន់ដែលត្រូវបណ្តុះគ្រាប់ពូជឲ្យបានគ្រប់គ្រាន់ដើម្បីឲ្យមានដើមសង្រ្កងស្វាពាសពេញដីល្អ។
- នៅពេលបញ្ចប់ដំណាក់កាលចេញផ្កាជាទូទៅចាប់ពី៥០ទៅ៦០ថ្ងៃក្រោយពេលបណ្តុះត្រូវជ្រោយដីឲ្យដំណាំនេះលាយចូលក្នុងដីដោយប្រើគ្រឿងយន្តឬដោយដៃ។ ទុកដីនេះចោលរយៈពេលពីរសប្តាហ៍ដើម្បីឲ្យដើមសង្រ្កងស្វាទាំងនេះរលួយបានល្អនៅក្នុងដី។
- ពីរសប្តាហ៍ក្រោយកូនម្ទេសអាយុមួយខែអាចយកទៅដាំជាធម្មតាបាន។
- រយៈពេលពេលនៃវដ្តផលិតកម្មនេះមានរយៈពេលប្រាំមួយខែ។
- នៅភាគឦសាននៃប្រទេសថៃវដ្តផលិតកម្ម (ការដាំដំណាំវិលជុំសង្រ្កងស្វា-ម្ទេស) អាចមានរយៈពេលមួយឆ្នាំហើយដីនៅតែអាចទុកទំនេរនៅរដូវប្រាំង។
- ចាំបាច់ត្រូវដាំដើមសង្រ្កងស្វានៅក្នុងកម្រិតដង់ស៊ីតេខ្ពស់និងដាំរហូតដល់ចេញផ្កាដើម្បីធានាឲ្យមានជីវម៉ាសគ្រប់គ្រាន់។

**រូបភាពទី៣៖ ប្រព័ន្ធឫសដើមម្ទេសដែលត្រូវបានកាត់ដោយដង្កូវស៊ីឫសនៅភាគខាងត្បូង nematode[៤]**



**រូបភាពទី៥៖ ប្រព័ន្ធឫសដើមម្ទេសដែលខូច (ខាងឆ្វេង) និងឫសដើមម្ទេសមានសុខភាពល្អ (ខាងស្តាំ)[៥]**



[៣] Kushida *et al.* (២០០៣)។ឥទ្ធិពលនៃដើម *Crotalaria juncea* និង *C. spectabilis* លើការបង្កាត់ពូជនិងដង់ស៊ីតេដង្កូវធ្វើឲ្យមានជំងឺពកនៅឫសដំណាំ (cyst)សណ្តែកសៀង, Heterodera glycines (Tylenchida៖ Heteroderidae)។ អនុវត្តបាណកវិទ្យានិងសត្តវិទ្យា. ៣៨ (៣)៖៣៩៣-៣៩៩។ មាននៅវែបសាយត៍ https://www.jstage.jst.go.jp/article/aez/38/3/38_3_393/_pdf

[៤] រូបថត៖ JIRCAS (២០០៨)។ ចំណុចសំខាន់ៗនៃការស្រាវជ្រាវ២០០៨។ ដើមសង្រ្កងស្វាមានប្រសិទ្ធភាពប្រឆាំងនឹងការបំផ្លាញដំណាំម្ទេសដោយដង្កូវ Nematodeនៅអាស៊ីអាគ្នេយ៍។ មាននៅវែបសាយត៍៖ http://www.jircas.affrc.go.jp/english/publication/highlights/2008/2008_11.html

[៥] រូបថត៖ A.M. Varela, icipe

## ទិដ្ឋភាពសេដ្ឋកិច្ច

- នៅក្នុងការសិក្សាថ្មីមួយ[៦]អ្នកអនុវត្តតាមអាចរកប្រាក់ចំណូលសុទ្ធបានចំនួន ២១៤.៤៣៧,៥០បាត (៧.២៦៥,១៤ដុល្លារអាមេរិក)។អ្នកមិនអនុវត្តតាមអាចរកប្រាក់ចំណូលសុទ្ធបានចំនួន១១៧.៨៧៨,១៣បាត (៣.៩៩៣,៧១ដុល្លារអាមេរិក)។

**តារាង១៖ ការប្រៀបធៀបថ្លៃដើមនិងទិន្នផលរបស់អ្នកអនុវត្តតាម និងអ្នកមិនអនុវត្តតាម**

| | អ្នកអនុវត្តតាម | អ្នកមិនអនុវត្តតាម |
|---|---|---|
| ថ្លៃដើម(បាត/ហិកតា) | ១៣៤៩០៣,១៣ ($៤៥៧០,៥២) | ១៣៤៩០៣,១៣ ($៤៥៧០,៥២) |
| ទិន្នផល(គីឡូក្រាម/ហិកតា) | ១១៩៧២ | ៧៧៥៩ |
| ចំណូលដុល (បាត/ហិកតា) | ៣៥២៤៦៥,៦៣ ($១១៩៤១,៥៤) | ២២៨៩០០ ($៧៧៥៥,១៣២) |
| ចំណូលសុទ្ធ (បាត/ហិកតា) | ២១៤៤៣៧,៥០ ($៧២៦៥,១៤) | ១១៧៨៧៨,១៣ ($៣៩៩៣,៧១) |

- ដោយសារកសិករមិនអាចដាំដំណាំតាមតម្រូវការទីផ្សារបាននៅពេលដាំដើមសង្រ្កងស្វានោះទើបឱកាសរកប្រាក់ចំណូលមួយចំនួនត្រូវបានខាតបង់។ ប៉ុន្តែការខាតបង់នោះត្រូវបានកាត់កងគ្នាជាមួយនឹងកំណើននៃទិន្នផលម្ទេស និងការលក់ម្ទេសនៅក្នុងរដូវនោះ។

## ទិដ្ឋភាពបរិស្ថាន

- ការកែលម្អជីវជាតិដីតាមរយៈការស្រូបយកអាសូតដោយដើមសង្រ្កងស្វានិងតាមរយៈសារធាតុចិញ្ចឹមពីរលួយសំណល់ដើមសង្រ្កងស្វា។
- បច្ចេកវិទ្យានេះមិនប្រើធនធានទឹកឡើយលើកលែងតែនៅក្នុងរដូវប្រាំងដែលចាំបាច់ត្រូវបូមទឹកដាក់។ពុំមានការផលិតសំណល់ទឹកឡើយ។
- កាត់បន្ថយការប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិត។
- បច្ចេកទេសនេះមិនប្រើប្រាស់ថាមពលណាមួយឡើយ។
- មុនពេលដាំដំបូងគ្រាប់ពូជដើមសង្រ្កងស្វាត្រូវទិញមកពីខាងក្រៅ។ បន្ទាប់មកកសិករអាចមានគ្រាប់ពូជច្រើននិងទុកគ្រាប់ពូជផ្ទាល់របស់ខ្លួនសម្រាប់ប្រើនៅរដូវក្រោយ។

## ទិដ្ឋភាពសង្គម

- មួយវដ្តផលិតកម្មមានសមាជិកគ្រួសារម្នាក់និងកម្មករប្រាំនាក់មកពីខាងក្រៅ។
- កសិករដែលប្រើប្រាស់បច្ចេកវិទ្យានេះមានតម្រូវការកម្មករខ្ពស់ជាងកសិករដែលដាំម្ទេសដោយប្រើប្រាស់ថ្នាំសម្លាប់សត្វល្អិតមានជាតិគីមី។
- បច្ចេកវិទ្យានេះសមស្របសម្រាប់ស្រ្តី៖នៅក្នុងប្រទេសថៃចំណែកស្ត្រីដែលប្រើប្រាស់បច្ចេកវិទ្យានេះមានចំនួន៥០ភាគរយ។
- បច្ចេកវិទ្យានេះអាចអនុវត្តលើផ្ទៃដីកសិកម្មនៅក្នុងទំហំណាមួយក៏បាន។

## បញ្ហាក្នុងការចម្លងយកទៅអនុវត្ត

- ការដាំដំណាំម្ទេសចម្រុះជាមួយដើម Crotalaria sp.មិនអាចកម្ចាត់ដង្កូវ Nematode បានគ្រប់គ្រាន់ឡើយដូច្នេះមិនណែនាំឲ្យអនុវត្តដូច្នេះឡើយ។
- ទោះបីជា *Crotalaria junea* ត្រូវបានប្រើប្រាស់ជាទូទៅដើម្បីធ្វើជាដំណាំជីបៃតងនៅក្នុងប្រទេសថៃក៏ដោយក៏ពេលខ្លះដំណាំនេះលំបាករកគ្រាប់ពូជដោយសារសត្វល្អិតបំផ្លាញនៅពេលចេញផ្កា។
- ដោយសារដើមសង្រ្កងស្វាមានប្រសិទ្ធភាពខ្ពស់ធ្វើជាជីបៃតងទើបមានការរំពឹងថាការប្រើប្រាស់ជីគីមីនិងដង្កូវ Nematode នឹងមានការថយចុះ។
- នៅក្នុងប្រទេសជប៉ុនមានការបង្ហាញថាដើមសង្រ្កងស្វាមានប្រសិទ្ធភាពខ្ពស់នៅលើស្ថានភាពដីផ្ទាល់ ជាជាងនៅក្នុងមន្ទីរពិសោធន៍។

## ជំនាញការ


- S. Miyata, N. Tangchitsomkid។ អ៊ីមែល៖ nuchanart@yahoo.com.
- Atsuhiko Kushida មន្ទីរពិសោធន៍ដង្កូវ Nematology ស៊ីវុទ្ធជាតិមជ្ឈមណ្ឌលជាតិស្រាវជ្រាវកសិកម្មសម្រាប់ តំបន់ហុកកៃដូ។ អ៊ីមែល៖ kushida@affrc.go.jp


## ទំនាក់ទំនង


បណ្ឌិត Tomohide Sugino តំណាងការិយាល័យទំនាក់ទំនងអាស៊ីអាគ្នេយ៍ JIRCAS។

អ៊ីមែល៖ tosugino@jircas.affrc.go.jp


## ប្រធានបទ

- ការផ្សាំម្រេច
- ការផ្សាំប៉េងប៉ោះ

[៦]Phompanjai, P. *et al.* (២០១២)។ ការកម្ចាត់ជំងឺឫសម្ទេសដែលបង្កឡើងដោយដង្កូវស៊ីឫស។ នៅក្នុង៖បន្លែមានតម្លៃខ្ពស់នៅអាស៊ីអាគ្នេយ៍៖ ផលិតកម្មការផ្គត់ផ្គង់ និងតម្រូវការ។ Proceedings, Seaveg ២០១២.១០៤-១០៨ទំព័រ១០៧១។

## ឯកសារបច្ចេកវិទ្យាកសិកម្មអាស៊ី SATNET

ឯកសារនេះផ្តល់ជូនព័ត៌មានអំពីបច្ចេកវិទ្យាកសិកម្មប្រកបដោយនិរន្តភាពឬទម្លាប់អនុវត្តល្អប្រសើរដែលបានបង្ហាញសក្តានុពលរបស់ខ្លួនក្នុងការលើកកម្ពស់ប្រសិទ្ធភាពធនធានផ្តល់អត្ថប្រយោជន៍សេដ្ឋកិច្ចនិងមានផលរំខានតិចតួចចំពោះសង្គម។ ឯកសារនេះគឺជាលទ្ធផលនៃការងារវិភាគដែលធ្វើឡើងដោយបណ្តាញផ្ទេរចំណេះដឹងអំពីបច្ចេកវិទ្យាកសិកម្មប្រកបដោយនិរន្តរភាព និងបណ្តាញទីផ្សារកាន់តែប្រសើរនៅអាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ (SATNET Asia)។ ដោយមានការពិគ្រោះយោបល់ជាមួយអ្នកចូលរួមមកពី SATNET Asia មជ្ឈមណ្ឌលសន្តិសុខស្បៀង (FSC) នៃសកលវិទ្យាល័យ Hohenheim ប្រទេសអាល្លឺម៉ង់បានដឹកនាំការបង្កើតក្របខ័ណ្ឌវិភាគដើម្បីវាយតម្លៃនិរន្តរភាព និងផលិតភាពដោយលើកកម្ពស់សក្តានុពលជម្រើសបច្ចេកវិទ្យាកសិកម្មដោយផ្អែកលើការពិនិត្យមើលយ៉ាងម៉ត់ចត់លើចំណេះដឹងវិទ្យាសាស្ត្រ។ ឧទាហរណ៍នៃជម្រើសបច្ចេកវិទ្យាត្រូវបានប្រមូលពីប្រភពផ្សេងៗជាច្រើនរួមទាំងអ្នកចូលរួមមកពី SATNET Asia ជំនាញការមកពីខាងក្រៅតំបន់និងច្រកចំណេះដឹងតាមអ៊ីនធឺណិតព្រមទាំងឯកសារផ្សេងៗ។ សម្រាប់បច្ចេកវិទ្យាដែលអាចរកបានព័ត៌មានគ្រប់គ្រាន់ក្របខ័ណ្ឌវិភាគត្រូវបានប្រើប្រាស់ដើម្បីគណនាសូចនាករនិរន្តរភាពសម្រាប់បច្ចេកវិទ្យានេះ។

## អំពី SATNET Asia

SATNET Asia គឺជាបណ្តាញដែលផ្តល់មូលនិធិដោយសហភាពអឺរ៉ុប។ បណ្តាញនេះត្រូវបានអនុវត្តដោយមជ្ឈមណ្ឌលកាត់បន្ថយភាពក្រីក្រតាមរយៈកសិកម្មនិរន្តរភាព (CAPSA) នៃគណៈកម្មការសេដ្ឋកិច្ច និងសង្គមនៃអង្គការសហប្រជាជាតិសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (UNESCAP) ដោយសហការជាមួយមជ្ឈមណ្ឌលផ្ទេរបច្ចេកវិទ្យាសម្រាប់អាស៊ី និងប៉ាស៊ីហ្វិក (APCTT), AVRDC មជ្ឈមណ្ឌលបន្លែពិភពលោកមជ្ឈមណ្ឌលសន្តិសុខស្បៀង (FSC) នៃសកលវិទ្យាល័យ Hohenheim  ព្រមទាំងផ្នែកពាណិជ្ជកម្មនិងវិនិយោគនៃ UNESCAP។

SATNET Asia  ត្រូវបានដាក់ឲ្យអនុវត្តនៅក្នុងឆ្នាំ២០១២ដើម្បីគាំទ្រដល់គំនិតច្នៃប្រឌិតដើម្បីកសិកម្មប្រកបដោយនិរន្តភាពតាមរយៈការពង្រឹងកិច្ចពិភាក្សាត្បូង-ត្បូង និងការសិក្សាទូទាំងតំបន់។ ដោយធ្វើប្រតិបត្តិការនៅក្នុងប្រទេសចំនួន១០នៃតំបន់អាស៊ីខាងត្បូងនិងអាស៊ីអាគ្នេយ៍ SATNET ធ្វើការសម្របសម្រួលការផ្ទេរចំណេះដឹងតាមរយៈការបង្កើតកម្រងឯកសារអនុវត្តល្អប្រសើរបំផុតអំពីកសិកម្មប្រកបដោយនិរន្តរភាពការសម្របសម្រួលពាណិជ្ជកម្មនិងការចែករំលែកចំណេះដឹងប្រកបដោយភាពច្នៃប្រឌិត។ ដោយផ្អែកលើចំណេះដឹងដែលបានចងក្រងជាឯកសារនេះ SATNET Asia ផ្តល់កម្មវិធីកសាងសមត្ថភាពដល់អ្នកចូលរួមបណ្តាញដែលដើរតួនាទីជាភ្នាក់ងារនិងអ្នកច្នៃប្រឌិតផ្លាស់ប្តូរដូចជាអង្គការកសិករពាណិជ្ជករវិស័យឯកជនវិស័យសាធារណៈ និងអ្នកបង្កើតគោលនយោបាយ។ ការអនុវត្តនេះនឹងអាចឲ្យអ្នកចូលរួមធ្វើការផ្ទេរចំណេះដឹងនេះទៅអ្នកដែលត្រូវការបំផុតពោលគឺកសិករដែលមានផ្ទៃដីដាំដុះតូចនិងសហគ្រាសខ្នាតតូច។

ដោយសារវិស័យសាធារណៈលែងគ្របដណ្តប់លើកិច្ចការអភិវឌ្ឍកសិកម្ម SATNET មានគោលបំណងច្បាស់លាស់ក្នុងការដាក់បញ្ចូលក្រុមដូចខាងក្រោមនៅក្នុងដំណើរការច្នៃប្រឌិត៖ សាកលវិទ្យាល័យក្រុមហ៊ុនឯកជនដែលបង្កើត និងលក់ផលិតផលបច្ចេកវិទ្យាឬផ្តល់សេវាសម្របសម្រួលពាណិជ្ជកម្មមូលនិធិកសិកម្មអង្គការកសិករ និងអង្គការមិនមែនរដ្ឋាភិបាល។ រួមជាមួយក្រុមគោលដៅទាំងនេះគម្រោងមានគោលដៅបង្កើតបរិយាកាសចំណេះដឹងដែលផ្តោតលើការកាត់បន្ថយភាពក្រីក្រ និងមាន លក្ខណៈអំណោយផលចំពោះការច្នៃប្រឌិតជាប្រចាំ និងប្រកបដោយនិរន្តរភាព។

**SATNET Asia**
CAPSA-ESCAP
Jl. Merdeka 145
Bogor 16111, ប្រទេសឥណ្ឌូនេស៊ី
ទូរស័ព្ទ៖ +62 251 8343277, 8356813
ទូរសារ៖ +62 251 8336290
អ៊ីមែល៖ satnet@satnetasia.org
**www.satnetasia.org**

គម្រោងនេះផ្តល់មូលនិធិដោយសហភាពអឺរ៉ុប

ឯកសារបោះពុម្ពផ្សាយនេះរៀបចំឡើងក្រោមជំនួយរបស់សហភាពអឺរ៉ុប។ ខ្លឹមសារនៃឯកសារបោះពុម្ពផ្សាយនេះ នឹងមានការទទួលខុសត្រូវទាំងស្រុងពី ESCAP ហើយអាចចាត់ទុកថាជាការឆ្លុះបញ្ចាំងអំពីទស្សនៈរបស់សហភាពអឺរ៉ុបមិនថានៅក្នុងស្ថានភាពណាឡើយ។